# ការបណ្ដុះគ្រាប់ស្រូវ

1



**ជំហានទី១ : ការយកសំណាក**

ការរើសសំណាក: ត្រូវរើសយកសំណាក ដោយចៃដន្យពីកន្លែងផ្សេងៗនៃបាវ ឬជង្រុក ។ ប្រសិនបើគ្រាប់ពូជនោះមានច្រើនបាវ ឬជង្រុក យើងត្រូវយកចេញពីបាវ ឬជង្រុកផ្សេងៗគ្នា។

2



**ជំហានទី២ : ការរៀបចំធ្វើតេស្ត**

ដាក់វត្ថុដែលជប់ទឹកបានច្រើនដូចជា សំឡី ក្រដាស់ ឬក្រណាត់ ទៅបាតចាន ឬថាស។ យកសំណាកគ្រាប់ពូជចំនួន១០០គ្រាប់ដែលបានរើសរួច ទៅដាក់លើសំឡី ក្រដាស ឬក្រណាត់ជប់ទឹកនោះ។ ផ្សើមក្រដាស់ ឬក្រណាត់ឲ្យបានជោកល្អ។

3



**ជំហានទី៣ : ការពិនិត្យមើលសំណើម**

ពិនិត្យមើលសំណើមនៅលើសំឡី ក្រដាស ឬក្រណាត់ជប់ទឹកនៅក្នុងចាន ឬថាសនោះឲ្យមានសំណើមជានិច្ច និងធ្វើការកត់ត្រាគ្រាប់ពូជដែលដុះទៅតាមថ្ងៃ រយៈពេល ៥ថ្ងៃ។

4



**ជំហានទី៤: ការរាប់គ្រាប់ដុះ និងគណនាអត្រាដំណុះ**

ធ្វើការរាប់គ្រាប់ដែលបានដុះសរុប ហើយធ្វើការគណនាតាមរូបមន្តខាងក្រោម។ ឧ: ប្រសិនបើមានគ្រាប់ពូជដែលបានដុះចំនួន ៨៥នៃគ្រាប់ពូជដែលមាននៅក្នុងថានពិសោធ១០០គ្រាប់ វាមានន័យថា គ្រាប់ពូជនោះដុះបាន ៨៥%។

អត្រាដំណុះ (%) = ចំនួនគ្រាប់ពូជដែលដុះ x ១០០ / ចំនួនគ្រាប់ពូជដែលមាននៅក្នុងថាន